# ពាក្យហៅសាច់ញាតិ ក្នុងសិលាចារឹកខ្មែរ (ភាគ១)

សាច់ញាតិ ជាអ្នករួមខ្សែលោហិតនឹងគ្នាខាងឪពុកម្ដាយ ឬភ្ជាប់សាច់ឈាមតាមរយៈអាពាហ៍ពិពាហ៍។ នៅសម័យបច្ចុប្បន្ននេះ យើងសង្កេតឃើញថា ខ្មែរមួយចំនួនចាប់ផ្ដើមទទួលយកពាក្យចិនមកប្រើប្រាស់សម្រាប់ហៅសាច់ញាតិ ដូចជាពាក្យ **ហ៊ា ចែ អ៊ី គូ/ហ្វូ**... ជាដើម។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញនូវពាក្យមួយចំនួនដែលខ្មែរប្រើហៅសាច់ញាតិនាសម័យបុរាណ តាមរយៈភស្តុតាងសិលាចារឹក។ ពាក្យភាគច្រើន នៅបន្តប្រើប្រាស់រហូតមកដល់បច្ចុប្បន្ន ដែលពាក្យខ្លះរក្សារូបរាងឬសូរដដែល ឯពាក្យខ្លះទៀតបានប្រែប្រួលរូបរាងឬសូរផងដែរ។

## ១- ពាក្យហៅជីដូនជីតា

**«ជិ»** ឬ **«ជី»** ជាពាក្យសម្គាល់ពីវ័យរបស់បុព្វការីខាងលើថ្នាក់ទី២។ ចំណែកឯពាក្យ **«អ្ជិ»** ឬ **«អ្ជី»** ជាពាក្យសម្រាប់សម្គាល់បុព្វការីជនខាងលើថ្នាក់ទី២ ដែលភាគច្រើនសម្គាល់មនុស្សប្រុស។ យើងឃើញថាពាក្យ **«អ្ជិ»** ឬ **«អ្ជី»** ពុំដែលមានប្រើជាមួយឈ្មោះបុគ្គលដែលជាជីតានោះទេ ដែលនេះជាចំណុចខុសប្លែកពី **«ជិ»** ឬ **«ជី»** ដែលតែងប្រើភ្ជាប់ខាងមុខឈ្មោះបុគ្គលឬឋានន្តរនាមរបស់បុគ្គលនោះ។ ពាក្យដែលប្រើនៅបន្ទាប់ **«អ្ជិ»** ឬ **«អ្ជី»** ច្រើនតែបញ្ជាក់ពីទំនាក់ទំនងជាញាតិសន្តានជាមួយពាក្យនេះ។ បច្ចុប្បន្នមិនប្រើពាក្យ «អ្ជី» នេះទេ ប្រើតែ «ជី» ម្យ៉ាងប៉ុណ្ណោះ[១]។

ឧ. - **អ្ជី**យេង៑ = ជីតាយើង, ជីតារបស់យើង។

- **អ្ជិ**វាបសហិ = ជីតាវាបសហ, ជីតារបស់វាបសហ។

- **អ្ជិ**មាត្ឫបក្សយេង៑ = ជីតាខាងម្ដាយយើង, ជីតារបស់យើងខាងម្ដាយ។

- **អ្ជិ**អញ៑តង្មោះ**ជិ**លោញ៑ជិណេទ្រនុ**ជិ**លោញ៑លេម = ជីតាអញឈ្មោះតាលោញជិណេទ្រនិងតាលោញលេស។

---

[១] ហ៊ុន ឈុនតេង ២០១៨: ៨៥-៨៦។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

«**អ្តា**» ជាពាក្យសម្រាប់សម្គាល់បុព្វការីជនខាងលើថ្នាក់ទី២ ដូច «**អ្និ**» ឬ «**អ្នី**» ដែរ មានន័យដូចពាក្យ «**តា**» នាពេលបច្ចុប្បន្ន។ «**អ្តា**» មិនប្រើនៅខាងដើមឈ្មោះមនុស្សដែលជាតានោះទេ។ ចំណែកឯពាក្យ «**តា**» ជាពាក្យប្រើសម្រាប់សម្គាល់វ័យរបស់បុព្វការីជនខាងលើថ្នាក់ទី២ផង និងអាចប្រើនៅខាងដើមឈ្មោះរបស់បុព្វការីនោះផង[២]។ ពាក្យ «**តា**» ភាគច្រើនឃើញប្រើនៅសម័យកណ្តាលប៉ុណ្ណោះ។

ឧ. - ទៅនិរយស្ថាន អ្និគេតសិ គេតកន្តែ អ្មេគេ **អ្តា**គេ កោនិចៅគេ (K.451N: 4)

= (ធ្លាក់)ទៅស្ថាននរក (ទាំង)ជីគេទាំងប្រុសទាំងស្រី ម៉ែគេ តាគេ កូនចៅគេ។

- ស្រែ**តា**សុកយាយខៀវតាកជាប្រពៃណីយវាតអតធ្វា (K.793 : 1-2)

= ស្រែតាសុក យាយខៀវ ដាក់ជាប្រពៃណីវត្តអធ្វា។

«**ត្វនិ**» និង «**តួន**» ជាពាក្យសម្គាល់វ័យរបស់បុព្វការីជនភេទស្រីខាងលើថ្នាក់ទី២។ ពាក្យនេះក្លាយមកជាពាក្យទំនើបថា «**ដូន**»។ ពាក្យ «**ត្វនិ**» ច្រើនប្រើជាមួយឋានន្តរនាម «**តេង៍**» សម្រាប់សម្គាល់មនុស្សស្រីវ័យចំណាស់ដូចជាជីដូនរបស់អ្នកអង្គម្ចាស់ អតីតស្រីស្នំ និងមេការក្នុងព្រះរាជវាំង[៣]។ អ្នកដែលជាប់សាច់ឈាមខ្សែខាងជីដូន ហៅថា «**កំតោនិ**» ឬ «**កំត្វនិ**» ដែលពាក្យនេះបានចូលរួមបង្កើតជាឋានន្តរនាមរបស់ព្រះមហាក្សត្រផងដែរ មានព្រះបាទសូរ្យវម៌្មទេវទី១ និងព្រះបាទឧទយាទិត្យវម៌្មទេវទី២។ ឋានន្តរនាមនោះគឺ «**វ្រះបាទកម្រតេងកំត្វនិអញ**» ដែលសម្រួលជាអក្ខរាវិរុទ្ធទំនើបបានថា «**ព្រះបាទតម្កែងកំដូនអញ**» គឺសំដៅដល់ព្រះមហាក្សត្រដែលឡើងសោយរាជ្យដោយជាប់ខ្សែខាងជីដូន។

ឧ. - តេង៍ចានិក្វនិលោញ៑ធន **ត្វនិ**អ្មោយបុរក្វនិតេង៍ច្វត (K.366B: 9-11)

= តេងចានកូនលោញធន ដូនអោ្មយបូរកូនតេងស្វត។

- **តេង៍ត្វនិ**តយាកំស្តេង៑ (K.257) = តេងដូនជាយាយកំស្តែង។

- បោញ៑គុកកីត្តិចៅ**កំតោនិ** (K.49:14) = បោញសុភកីត្តិជាចៅខាងជីដូន។

---

[២] ហ៊ុន ឈុនតេង ២០១៨: ៨៦។

[៣] វង់ សុធារ៉ា ២០១៦: ១៧។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

**«យ»** ឬ **«យា»** ជាពាក្យសម្រាប់ហៅ **«យាយ»**។ ពាក្យនេះស្ថិតក្នុងស្រឡាយពាក្យ **«យិ»** ឬ **«យី»** និង **«យេ»** ដែលត្រូវនឹងពាក្យ **«ញី»** សម័យបច្ចុប្បន្ននេះ។ ពាក្យ **«យ»** ក៏ឃើញមានប្រើនៅក្នុងភាសាមនបុរាណ ដែលប្រើដាក់នៅខាងដើមអសាធារណនាមមនុស្សស្រី[៨]។ នៅសម័យមុនអង្គរ ពាក្យ **«យ»** នេះ ច្រើនប្រើជាឋានន្តរនាម **«កុយ»** ដែលប្រើសម្គាល់អ្នកបម្រើភេទស្រី មានវ័យចំណាស់។ ពាក្យ **«យ៉ា»** នៅក៏មានប្រើជារាជសព្ទសម្រាប់សៃរាជវង្សហៅព្រះអយ្យិកា ឬព្រះអយ្យិកាទួតផងដែរ គឺ **«ស្ដេចយ៉ា»**។ នៅក្នុងស្រទាប់រាស្ត្រសាមញ្ញ ក៏មានប្រើពាក្យនេះជាគុណនាម បញ្ជាក់ពីសភាពលក្ខណៈចាស់របស់មនុស្ស **«ចាស់យ៉ា»**។

ឧ. - **យា**កំម្រតេងអញ្ញរាជបុត្រ (K.192: 4) = ព្រះអយ្យិការបស់គម្តែងអញរាជបុត្រ។

- តេងត្វនិត**យា**កំស្តេង (K.257) = តេងជូនជាយាយកំស្តែង។

## ២- ពាក្យហៅឪពុកម្ដាយ

មានពាក្យពីរសម្រាប់ហៅទាក់ទឹងម្ដាយ គឺ **«អ្មេ»** និង **«មេ»**។ ជាទូទៅ យើងសង្កេតឃើញថា **«អ្មេ»** មិនប្រើជាមួយឈ្មោះបុគ្គលនោះទេ ហើយពាក្យឬឈ្មោះដែលប្រើនៅខាងក្រោយ គឺសម្ដែងពីទំនាក់ទំនងសាច់ឈាមជាញាតិសន្តានជាមួយនឹង **«អ្មេ»** នោះ។ ចំណែកឯ **«មេ»** វិញគឺប្រើជាមួយឈ្មោះបុគ្គល ដើម្បីបង្ហាញពីចំណាស់របស់បុគ្គលនោះ[៩]។ ពាក្យ **«មេ»** ក្លាយជាពាក្យ **«មេ»** ផង **«ម៉ែ»** ផង និងក្លាយទៅជា **«មី»** ផង។

KHMER CIVILIZATION

ឧ. - វាបិយោលំបញ្ចូលិលកិស្រេនេះត**មេ**នំតអ្ហិវាបសហិ (K.158B : 20)

= វាបយោរលំបញ្ចូល់លក់ស្រែនេះដល់ម៉ែនើមជាជី(ជូន)វាបសហ។

- ភូម្យនុស្រេមនិជោតវាបិអ្យកិនុ**អ្មេ**កុលេវាបិអ្យកជោង (K.212B : 1-2)

= ភូមិនិងស្រែដែលជារពីវាបអ្យកនិងម្ដាយគ្រួសារវាបអ្យកផង។

---

[៨] Jenner 2009: 382។

[៩] វង់ សុធារ៉ា ២០១៦: ៨៧។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## បញ្ជីឯកសារយោង


វង់ សុធារ៉ា

២០១៦. សិលាចារឹកនៃប្រទេសកម្ពុជាសម័យអង្គរ. ការផ្សាយលើកទី២។

ហ៊ុន ឈុនតេង

២០១៨. សិលាចារឹកទួលប្រាសាទអំបែងបេះ K.1365. ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា. លេខពិសេស ឆ្នាំទី៦៥ លេខ៤។

Jenner, P. N.

2009. *A dictionary of pre-Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.


## បញ្ជីរូបភាព









អត្ថបទដោយៈ ហ៊ិន ឈុនតេង